1998/60- ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

គណៈកម្មការសិទ្ធិមនុស្ស

ណែនាំដោយទិសដៅ និងគោលការណ៍ ដែលមានចែងនៅក្នុងធម្មនុញ្ញសហប្រជាជាតិ សេចក្តីថ្លែងការណ៍ជាសកលស្តីអំពីសិទ្ធិមនុស្ស ហើយនឹងអនុសញ្ញាអន្តរជាតិនានាស្តីអំពីសិទ្ធិមនុស្ស

រំលឹកឡើងវិញ កិច្ចព្រមព្រៀងស្តីពីការដោះស្រាយនយោបាយដោយសព្វមុខនៃជម្លោះកម្ពុជា ចុះហត្ថលេខានៅទីក្រុងប៉ារីស៍ នៅថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៩៩១ ក្នុងនោះរួមមានជំពូកទី ៣ ពាក់ព័ន្ធនឹងបញ្ហាសិទ្ធិមនុស្ស

រំលឹកឡើងវិញ សេចក្តីសំរេចចិត្តរបស់ខ្លួនលេខ ១៩៩៧/៤៩ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ១៩៩៧ សេចក្តីសំរេចចិត្តរបស់មហាសន្និបាតលេខ ៥២/១៣៥ ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ១៩៩៧ ហើយនឹងសេចក្តីសំរេចចិត្តមានពាក់ព័ន្ធនានាកាលពីមុន ៗ មក ក្នុងនេះរួមមានសេចក្តីសំរេចចិត្តរបស់គណៈកម្មការលេខ ១៩៩៣/៦ ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៣ ដែលនៅក្នុងសេចក្តីសំរេចចិត្តនោះ គណៈកម្មការបានស្នើឱ្យលោកអគ្គលេខាធិការតែងតាំងតំណាងពិសេសម្នាក់របស់លោកប្រចាំប្រទេសកម្ពុជា ហើយនឹងការតែងតាំងជាបន្ទាប់មកនូវតំណាងពិសេសមួយរូប

ទទួលស្គាល់ថា ប្រវត្តិសាស្ត្រប្រកបដោយសោកនាដកម្មរបស់ប្រទេសកម្ពុជា ទាមទារឱ្យមានវិធានការពិសេស ដើម្បីធានាការការពារសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងប្រទេសកម្ពុជា និងការមិនវិលត្រឡប់មកវិញនូវនយោបាយ និងការអនុវត្តន៍ពីអតីតកាល ដូចដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងចុះហត្ថលេខានៅទីក្រុងប៉ារីស៍ នៅក្នុងឆ្នាំ ១៩៩១

មានបំណងចង់ឱ្យអង្គការសហប្រជាជាតិឆ្លើយតបជាវិជ្ជមាន ក្នុងការជួយដល់កិច្ចខិតខំដើម្បីធ្វើការស៊ើបអង្កេតទៅលើប្រវត្តិសាស្ត្រប្រកបដោយសោកនាដ្យកម្មរបស់ប្រទេសកម្ពុជា រួមមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មជាអន្តរជាតិពីអតីតកាល ដូចជាអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាដើម

ស្វាគមន៍ ចំពោះការបន្តនូវតួនាទី និងទស្សនៈកិច្ចនៅកម្ពុជាកាលពីខែមករា ឆ្នាំ ១៩៩៨ របស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជំរុញ និងការការពារសិទ្ធិមនុស្ស នៅក្នុងប្រទេសកម្ពុជា

១- សុំឱ្យលោកអគ្គលេខាធិការ តាមរយៈតំណាងពិសេសទទួលបន្ទុកសិទ្ធិមនុស្សរបស់លោកប្រចាំកម្ពុជា ដោយសហការជាមួយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ជួយដល់រដ្ឋាភិបាលកម្ពុជាក្នុងការធានាការការពារសិទ្ធិមនុស្ស របស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងប្រទេសកម្ពុជា និងធានាឱ្យមានធនធានគ្រប់គ្រាន់សំរាប់បង្កើនកិច្ចដំណើរការនៃវត្តមានប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា របស់ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស និងសំរាប់ឱ្យលោកតំណាងពិសេសអាចបន្តបំពេញកិច្ចការរបស់លោកប្រកបដោយប្រសិទ្ធភាព ។

២- ស្វាគមន៍របាយការណ៍របស់លោកអគ្គលេខាធិការ ស្តីអំពីតួនាទីរបស់ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការជំរុញ និងការការពារសិទ្ធិមនុស្ស (A/52/489, sect.111) ហើយនឹងលើកទឹកចិត្តរដ្ឋាភិបាលកម្ពុជាឱ្យបន្តសហការជាមួយការិយាល័យនេះជាបន្តទៅទៀត ជាពិសេសក្នុងដំណើរការឆ្ពោះទៅការបោះឆ្នោតជាតិនាពេលខាងមុខនេះ ។

៣- ស្វាគមន៍ផងដែរកិច្ចព្រមព្រៀងរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការបន្តអាណត្តិរបស់ការិយាល័យប្រចាំទីក្រុងភ្នំពេញ នៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ដែលនឹងធ្វើឱ្យការិយាល័យនេះអាចបន្តកិច្ចប្រតិបត្តិការ និងរក្សាបាននូវកម្មវិធីសហប្រតិបត្តិការបច្ចេកទេសរបស់ខ្លួនតទៅទៀតបានផង ។

៤- លើកទឹកចិត្តរដ្ឋាភិបាលកម្ពុជា ឱ្យសុំមកការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដើម្បីឱ្យជួយផ្តល់ជាយោបល់ និងជាជំនួយបច្ចេកទេស ក្នុងការបង្កើតឡើងនូវស្ថាប័នជាតិឯករាជ្យមួយ សំរាប់ការជំរុញ និងការការពារសិទ្ធិមនុស្ស ហើយនឹងឈានទៅបង្កើតឡើងនូវស្ថាប័នមួយបែបនេះ ។

៥- កត់សំគាល់ដោយពេញចិត្ត របាយការណ៍របស់លោកតំណាងពិសេសស្តីអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (E/CN.4/1998/95) ជាពិសេសការព្រួយបារម្ភរបស់លោកចំពោះបញ្ហានិទ័ណ្ឌភាព បញ្ហាឯករាជ្យភាពរបស់តុលាការ និងការបង្កើតឡើងនូវវិធាននៃច្បាប់ ការប្រើប្រាស់ទារុណកម្ម ការគ្រប់គ្រងព័ន្ធនាគារ និងប្រព្រឹត្តកម្មយង់ឃ្នងលើអ្នកទោស ហើយនឹងបញ្ហាពេស្យាកម្ម និងការជួញដូរកុមារ ។

៦- សំដែងនូវសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង ចំពោះករណីជាច្រើននៃការរំលោភសិទ្ធិមនុស្ស រួមមានការសម្លាប់ក្រៅច្បាប់ ទារុណកម្ម ការចាប់រំលោភ ការចាប់និងការឃុំខ្លួនដោយខុសច្បាប់ ហើយនឹងអំពើហឹង្សាទាក់ទិនទៅនឹងសកម្មភាពនយោបាយ ក្នុងនេះរួមមានអំពើហឹង្សានាខែមិនា ឆ្នាំ ១៩៩៧ និង ខែកក្កដា ឆ្នាំ ១៩៩៧ ដូចដែលបានរាយការណ៍លំអិតនៅក្នុងរបាយការណ៍នានារបស់លោកតំណាងពិសេស ហើយអំពាវនាវដល់រដ្ឋាភិបាលកម្ពុជា សូមឱ្យធ្វើការស៊ើបអង្កេតជាបន្ទាន់ និងធ្វើការកាត់ទោស ស្របទៅតាមនីតិវិធីច្បាប់ និងបទដ្ឋានអន្តរជាតិទាក់ទិនទៅនឹងសិទ្ធិមនុស្ស នូវជនទាំងអស់ដែលបានប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្ស ។

៧- សំដែងនូវការព្រួយបារម្ភយ៉ាងខ្លាំងផងដែរ ចំពោះស្ថានភាពនៃនិទ័ណ្ឌភាពនៅក្នុងប្រទេសកម្ពុជា ហើយនឹងគូសបញ្ជាក់ថាការដោះស្រាយបញ្ហានិទ័ណ្ឌភាពដែលចេះតែកើតមានជាបន្តដូចដែលបានរៀបរាប់ដោយលំអិតដោយលោកតំណាងពិសេស ក្នុងនោះរួមមានការលប់ចោលមាត្រាទី ៥១ នៃច្បាប់ស្តីពីមន្ត្រីរាជការស៊ីវិល ឆ្នាំ ១៩៩៤ ហើយនឹងការនាំខ្លួនទៅកាន់តុលាការនូវជនទាំងឡាយណាដែលទទួលខុសត្រូវក្នុងការរំលោភសិទ្ធិមនុស្ស ព្រមជាមួយនឹងការធានាឱ្យមានសន្តិសុខចំពោះមនុស្ស និងសិទ្ធិបង្កើតសមាគម សិទ្ធិធ្វើការប្រជុំ ហើយនឹងសេរីភាពក្នុងការសំដែងមតិ នៅតែស្ថិតនៅជាបញ្ហាមួយជាអាទិភាពសំខាន់ និងបន្ទាន់ ហើយនឹងជាបញ្ហាសំខាន់ណាស់ក្នុងការបង្កើតឡើងនូវបរិយាកាសមួយនាំទៅឱ្យមានការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងដែលអាច ទទួលយកបាន ។

៨- ស្វាគមន៍ចំពោះក្របខ័ណ្ឌច្បាប់ដែលបានអនុម័តដោយរដ្ឋសភា ហើយអំពាវនាវឱ្យមានការកោះប្រជុំក្រុមប្រឹក្សាធម្មនុញ្ញឱ្យបានឆាប់បំផុតដែលអាចធ្វើទៅបាន អំពាវនាវឱ្យមានបរិយា-កាសនយោបាយដោយពុំមានការបំភិតបំភ័យនៅមុនពេល និងក្នុងពេលបោះឆ្នោត អំពាវនាវឱ្យកងកម្លាំងប្រដាប់អាវុធស្ថិតនៅអព្យាក្រិត អំពាវនាវឱ្យមានការប្រើប្រាស់ដោយសេរី និងដោយស្មើភាពគ្នានូវប្រព័ន្ធផ្សាយពិតមានអេឡិចត្រូនិក និងការបោះពុម្ពផ្សាយ សំរាប់គណៈបក្សនយោបាយទាំងអស់ អំពាវនាវសូមឱ្យសន្លឹកឆ្នោតរបស់បុគ្គលម្នាក់ ៗ ស្ថិតនៅជាការសម្ងាត់ អំពាវនាវឱ្យមានការផ្តល់នូវកិច្ចសហប្រតិបត្តិការដ៏ពេញលេញចំពោះអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ហើយនឹងអំពាវនាវឱ្យគ្រប់គណៈបក្សនយោបាយទាំងអស់ធ្វើសកម្មភាពមានលក្ខណៈស្ថាបនា ហើយនឹងយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត ។

៩- ស្វាគមន៍ផងដែរការវិលត្រឡប់នៃអ្នកដឹកនាំនយោបាយមកពីក្រៅប្រទេស ដែលជាការទាមទារជាគន្លឹះមួយឆ្ពោះទៅឱ្យមានកិច្ចដំណើរការបោះឆ្នោតមួយ ដែលអាចទទួលយកបាននោះ ហើយស្វាគមន៍តួនាទីរបស់ការិយាល័យរបស់លោកអគ្គលេខាធិការប្រចាំទីក្រុងភ្នំពេញ ក្នុងការតាម

ដានត្រួតពិនិត្យការវិលត្រឡប់នៃអ្នកដឹកនាំនយោបាយ ហើយនឹងការចាប់ផ្តើមធ្វើសកម្មភាពនយោបាយជាបន្តទៅទៀតរបស់ពួកគេ ។

១០- ស្វាគមន៍ថែមទៀតសេចក្តីសំរេចរបស់លោកអគ្គលេខាធិការ ទទួលយកការអញ្ជើញរបស់រដ្ឋាភិបាលកម្ពុជា ឱ្យអង្គការសហប្រជាជាតិដើរតួនាទីជាអ្នកសំរបសំរួលអ្នកសង្កេតការណ៍អន្តរជាតិចំពោះការបោះឆ្នោត ដែលគ្រោងនឹងធ្វើនៅខែកក្កដា ឆ្នាំ ១៩៩៨ ខាងមុខនេះ ។

១១- អំពាវនាវដល់រដ្ឋជាសមាជិក សូមឱ្យចូលរួមវិភាគទានក្នុងកិច្ចដំណើរការបោះឆ្នោត ក្នុងនេះរួមមានតាមរយៈការផ្តល់ជំនួយសំរាប់ការបោះឆ្នោត ការផ្តល់អ្នកសង្កេតការណ៍ការបោះឆ្នោត ហើយនឹងការរួមវិភាគទានចំពោះមូលនិធិនៃការរួមវិភាគទានដោយស្ម័គ្រចិត្ត ។

១២- ស្វាគមន៍កិច្ចឈប់បាញ់ និងអំពាវនាវដល់ភាគីកម្ពុជាទាំងអស់ឱ្យអនុវត្តដោយពេញលេញនូវខ្លឹមសារនៃកិច្ចឈប់បាញ់នេះ ហើយនឹងឱ្យសំរួលដល់សមាហរណកម្មអង្គភាពទាំងអស់មកក្នុងកងកម្លាំងប្រដាប់អាវុធកម្ពុជា និងធានាសុវត្ថិភាពរបស់ពួកគេ

១៣- អំពាវនាវដល់រដ្ឋាភិបាលកម្ពុជា ដែលជាភាគីមួយនៃអនុសញ្ញាស្តីអំពីការលុបបំបាត់នូវគ្រប់រូបភាពនៃការរើសអើងប្រឆាំងស្ត្រីភេទ ឱ្យចាត់វិធានការសមស្របលុបបំបាត់ការរើសអើងប្រឆាំងស្ត្រីភេទ ក្នុងនេះរួមមានការរួមចំណែកក្នុងជីវភាពនយោបាយ និងសាធារណៈរបស់ប្រទេស ហើយនឹងប្រយុទ្ធនឹងអំពើហិង្សាប្រឆាំងទៅលើស្ត្រីតាមគ្រប់រូបភាពផង ។

១៤- អំពាវនាវដល់រដ្ឋាភិបាលកម្ពុជា ឱ្យចាត់វិធានការជាក់ស្តែងប្រយុទ្ធនឹងពេស្យាកម្ម នឹងការជួញដូរកុមារ ហើយក្នុងន័យនេះធ្វើការជាមួយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជា

ជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា មូលនិធិសំរាប់កុមាររបស់អង្គការសហប្រជាជាតិ ហើយនឹងអង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីអភិវឌ្ឍន៍នូវគំរោងការណ៍សកម្មភាពមួយឡើង ។

១៥- សំដែងការសរសើរដល់រដ្ឋាភិបាល និងប្រជាពលរដ្ឋថៃ ចំពោះជំនួយមនុស្សធម៌ដល់អ្នកផ្លាស់ប្តូរទីកន្លែងមកពីប្រទេសកម្ពុជា ស្វាគមន៍តួនាទីរបស់ទីភ្នាក់ងារអង្គការសហប្រជាជាតិទាំងឡាយក្នុងការធ្វើមាតុភូមិនិវត្តន៍ជនភៀសខ្លួន និងមនុស្សផ្លាស់ប្តូរទីកន្លែង ហើយអំពាវនាវដល់រដ្ឋាភិបាលកម្ពុជា ឱ្យធានាសមាហរណកម្មដ៏ពេញលេញរបស់ពួកគេមកក្នុងសង្គមជាតិកម្ពុជា និងជីវភាពនយោបាយវិញ ហើយជាពិសេសខិតខំដោយអស់ពីចិត្តពីថ្លើមដើម្បីធ្វើយ៉ាងណាឱ្យពួកគេអាចចូលរួមក្នុងការបោះឆ្នោតនាពេលខាងមុខនេះកុំបីខាន ។

១៦- ស្វាគមន៍ការចុះហត្ថលេខាកាលពីខែឧសភា ឆ្នាំ ១៩៩៧ កន្លងទៅនេះ លើអនុស្សរណៈនៃកិច្ចព្រមព្រៀងមួយរវាងអង្គការការងារអន្តរជាតិ និងរដ្ឋាភិបាលកម្ពុជា ដើម្បីសំរបច្បាប់ឱ្យកិច្ចសហប្រតិបត្តិការក្នុងវិស័យការងារកុមារ ។

១៧- កត់សំគាល់ដោយយកចិត្តទុកដាក់ អត្ថាធិប្បាយរបស់លោកតំណាងពិសេសស្តីអំពីប្រព័ន្ធតុលាការ និងការគ្រប់គ្រងព័ន្ធនាគារ ហើយអំពាវនាវយ៉ាងទទូចឱ្យរដ្ឋាភិបាលកម្ពុជាបង្កើនកិច្ចខិតខំរបស់ខ្លួន ដើម្បីបង្កើតឡើងនូវប្រព័ន្ធតុលាការមួយដែលអាចដំណើរការបាន និងមិនលំអៀង ក្នុងនេះរួមមានការកោះប្រជុំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយនឹងដើម្បីបង្កើតឡើងនូវប្រព័ន្ធមួយធានានូវការផ្តត់ផ្គង់ដ៏ចាំបាច់ដល់អ្នកទោស និងបន្តកិច្ចខិតខំរបស់ខ្លួនដើម្បីកែលំអបរិស្ថានរូបវន្តរបស់ព័ន្ធនាគារ ។

១៨- សំដែងនូវការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះដ៏មហន្តរាយនៃការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស នៅក្នុងសង្គមកម្ពុជា ហើយជំរុញឱ្យរដ្ឋាភិបាលកម្ពុជាបន្តការខិតខំរបស់ខ្លួនក្នុងការដោះ

មីនទាំងនេះ ហើយនឹងផ្តល់នូវអាទិភាពក្នុងការអនុមតិពង្រាងច្បាប់ស្តីពីការហាមឃាត់ការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្សទាំងអស់ ។

១៩- យល់ស្របចំពោះអត្ថាធិប្បាយរបស់លោកតំណាងពិសេស ដែលថាការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរជាងគេបំផុតនៅក្នុងប្រទេសកម្ពុជា នៅក្នុងប្រវត្តិសាស្ត្រថ្មី ៗ កន្លងទៅនេះ ត្រូវបានប្រព្រឹត្តឡើងដោយពួកខ្មែរក្រហម ហើយថាឧក្រិដ្ឋកម្មរបស់ពួកគេ ក្នុងនេះរួមមានការចាប់ និងការសម្លាប់ចំណាប់ខ្មាំង កំពុងតែបន្តធ្វើនាពេលបច្ចុប្បន្ននេះ ហើយកត់សំគាល់ដោយយកចិត្តទុកដាក់ថាពុំមានមេដឹកនាំខ្មែរក្រហមណាម្នាក់ ត្រូវបានចាប់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ពួកគេនេះទេ ។

២០- ស្នើសុំឱ្យលោកអគ្គលេខាធិការពិនិត្យការស្នើសុំទាំងឡាយរបស់អាជ្ញាធរកម្ពុជា ក្នុងការឆ្លើយតបទៅនឹងការរំលោភដ៏ធ្ងន់ធ្ងរពីអតីតកាល ទៅលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ រួមមានលទ្ធភាពឱ្យមានការតែងតាំងដោយលោកអគ្គលេខាធិការ នូវក្រុមអ្នកជំនាញការមួយក្រុមដើម្បីធ្វើការវាយតម្លៃទៅលើភស្តុតាងទាំងឡាយដែលមានស្រាប់ ហើយនឹងលើកឡើងនូវវិធានការបន្ថែម ដើម្បីជាមធ្យោបាយមួយនាំទៅឱ្យមានការបង្រួបបង្រួមជាតិ ការពង្រឹងលទ្ធិប្រជាធិបតេយ្យ ហើយនឹងដោះស្រាយបញ្ហានៃការទទួលខុសត្រូវរបស់បុគ្គល ។

២១- លើកទឹកចិត្តដល់រដ្ឋាភិបាលកម្ពុជា ឱ្យបញ្ចូលអង្គការការពារសិទ្ធិមនុស្សក្រៅរដ្ឋាភិបាលកម្ពុជានានា ទៅក្នុងការធ្វើនីតិសម្បទា និងការកសាងប្រទេសកម្ពុជាឡើងវិញ ។

២២- កត់សំគាល់ដោយពេញចិត្ត ការប្រើប្រាស់ដោយលោកអគ្គលេខាធិការ នូវមូលនិធិនៃការរួមវិភាគទានដោយស្មគ្រចិត្តរបស់អង្គការសហប្រជាជាតិ សំរាប់កម្មវិធីអប់រំសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ដើម្បីផ្តល់ជាហិរញ្ញប្បទានដល់កម្មវិធីសកម្មភាពរបស់ការិយាល័យប្រចាំកម្ពុជានៃ

ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដូចដែលបានកំណត់នៅក្នុងសេចក្តីសំរេចចិត្តរបស់មហាសន្និបាត និងរបស់គណៈកម្មការសិទ្ធិមនុស្ស ហើយសូមអំពាវនាវដល់រដ្ឋាភិបាល អង្គការអន្តររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល មូលនិធិ និងឯកជន នានា សូមជួយផ្តល់វិភាគទានដល់មូលនិធិនៃការរួមវិភាគទានដោយស្ម័គ្រចិត្តផង ។

២៣- ស្នើសុំលោកអគ្គលេខាធិការរាយការណ៍ជូនគណៈកម្មការសិទ្ធិមនុស្ស នាសម័យប្រជុំលើកទី ៥៥ ស្តីអំពីតួនាទីរបស់ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការជំរុញ និងការការពារសិទ្ធិមនុស្ស ហើយនឹងស្តីអំពីអនុសាសន៍របស់លោកតំណាងពិសេសចំពោះបញ្ហាទាំងឡាយ ដែលស្ថិតនៅក្នុងអាណត្តិរបស់លោក ។

២៤- សំរេចបន្តការយកចិត្តទុកដាក់របស់ខ្លួន ចំពោះស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា នៅក្នុងសម័យប្រជុំរបស់ខ្លួនលើកទី ៥៥ ក្រោមរបៀបវារៈដែលមានចំណងជើងថា "សេវាទីប្រឹក្សា ក្នុងវិស័យសិទ្ធិមនុស្ស" ។

សម័យប្រជុំលើកទី ៥២

ថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៩៨

( អនុម័តដោយពុំមានធ្វើការបោះឆ្នោត)